ក

# មាតិកា

## I.ខុទ្ទកាល័យព្រះមហាក្សត្រ

### ១.ព្រះរាជក្រម


០៩-៣-២០០៦ -ព្រះរាជក្រម នស/រកម/០៣០៦/០០៦ ស្តីពីការប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ៨២ មាត្រា ៨៨ថ្មី មាត្រា ៩០ថ្មី មាត្រា ៩៨ មាត្រា ១០៦ថ្មី មាត្រា ១១១ថ្មី (មួយ) មាត្រា ១១៤ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ១៤២៩


### ២.ព្រះរាជក្រឹត្យ


២៤-០២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០២០៦/០៩៣ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ញាតូបនីយកម្ម ដល់លោក **ស៊ិន ហ៊ីតជេស៊ិន** (SHEN HEATH JASON) ជនជាតិអាមេរិក សញ្ជាតិអាមេរិក កើតនៅរដ្ឋកាលីហ្វ័រនីញ៉ា សហរដ្ឋអាមេរិក ១៤៣១

០៣-៣-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៣០៦/១០៧ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សប្ញទ្ធិ ជូនមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ចំនួន ០៣ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ ១៤៣២

០៣-៣-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៣០៦/១០៨ស្តីពីការប្រោសព្រះរាជទានចំពោះឯកឧត្តម ឧត្តមសេនីយ៍ឯក **មល់ រឿប** នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ១៤៣៣


## II.រាជរដ្ឋាភិបាល

### អនុក្រឹត្យ


០៩-៣-២០០៦ -អនុក្រឹត្យលេខ ១៥៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៤៣៤

០៩-៣-២០០៦ -អនុក្រឹត្យលេខ ១៥៤ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ១៤៣៦

០៩-៣-២០០៦ -អនុក្រឹត្យលេខ ១៥៥ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១៤៣៧

០៩-៣-២០០៦ -អនុក្រឹត្យលេខ ១៥៦ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១៤៤០

០៩-៣-២០០៦ -អនុក្រឹត្យលេខ ១៥៧ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១៤៤២

០៩-៣-២០០៦ -អនុក្រឹត្យលេខ ១៥៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១៤៤៤

## III~ការងារបណ្ដាក្រសួង

### ១~ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

០៩-៣-២០០៦ -ប្រកាសលេខ ២៧៩ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **នីមបឹស ថិចថាយ (ខេមបូឌា)** បង្កើតរោងចក្រ " កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា " នីមបឹស ថិចថាយ (ខេមបូឌា)" ១៤៤៧

### ២~ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

០២-០២-២០០៦ -លិខិតលេខ ៤០៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ជីង ជុន** ១៤៤៩

០៣-០២-២០០៦ -លិខិតលេខ ៤០៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទើនស៊ី (ខេមបូឌា) អន្តរជាតិ ខូ អិលធីឌី** ១៤៥១

០៣-០២-២០០៦ -លិខិតលេខ ៤០៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន**ខូឆាយណា ឡូជីស្ទីក(ខេមបូឌា)** ១៤៥៣

០៣-០២-២០០៦ -លិខិតលេខ ៤០៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមបូឌាន អ៊ិនធើណេសិនណល ហ្វៀនដេសិន លីមីធីត** ១៤៥៥

០៣-០២-២០០៦ -លិខិតលេខ ៤១២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យ៉ុង ឆាំង ឌីវេឡុបមេន** ១៤៥៦

០៧-០២-២០០៦ -លិខិតលេខ ៤២០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ណាត ហ្វូលឌីង (ខ្មែរ) លីមីធីត** ១៤៥៨

០៩-០២-២០០៦ -លិខិតលេខ ៤២៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ ក្រុមហ៊ុន **អ៊ី.យ៉ុង អ៊ិនធើណេសិនណល (ខេមបូឌា) ហ្គាមេន** ១៤៦០

០៩-០២-២០០៦ -លិខិតលេខ ៤២៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អង្គរ ស្ព៉ាយស៍ អ៊ីមផត អិចផត** ១៤៦២

០៩-០២-២០០៦ -លិខិតលេខ ៤២៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **លីម ជី គ្រុប** ១៤៦៤

០៩-០២-២០០៦ -លិខិតលេខ ៤៣១ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេវ៉ាដ៏រ មេឌា** ១៤៦៦

០៩-០២-២០០៦ -លិខិតលេខ ៤៣៨ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គ្វាន់ ស៊ីង (ខេមបូឌា)** ១៤៦៨

# ព្រះរាជក្រម

នស/រកម/០៣០៦/០០៦

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សំណើរបស់តំណាងរាស្ត្រចំនួនលើសពីមួយភាគបួននៃចំនួនតំណាងរាស្ត្រទាំងមូល
- បានទ្រង់យល់លិខិតលេខ ៨២ លស ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៦ របស់សម្តេចនាយករដ្ឋមន្ត្រី
- បានទ្រង់យល់លិខិតលេខ ០០១/០១/២០០៦ កបធ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៦ របស់ក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជសារព្រះមហាក្សត្រចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៦
- បានទ្រង់យល់លិខិតលេខ ២៥៤ រស ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០៦ របស់រដ្ឋសភា
- បានទ្រង់យល់លិខិតលេខ ០១៣/០៣០៦/៣ស/ឧវ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ២០០៦ របស់ព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## ប្រកាសឱ្យប្រើ

ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា៨២ មាត្រា៨៨ថ្មី មាត្រា៩០ថ្មី មាត្រា៩៨ មាត្រា១០៦ថ្មី មាត្រា១១១ថ្មី(មួយ) មាត្រា១១៤ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដែលរដ្ឋសភាអនុម័តនៅថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យច្បាប់នេះឱ្យទាន់តាមការកំណត់របស់មាត្រា១១៣ថ្មីនៃរដ្ឋធម្មនុញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់ធម្មនុញ្ញ
# ស្តីពី
# វិសោធនកម្ម
# មាត្រា ៨២ មាត្រា ៨៨ថ្មី មាត្រា ៩០ថ្មី មាត្រា ៩៨ មាត្រា ១០៦ថ្មី មាត្រា ១១១ថ្មី(មួយ) មាត្រា ១១៤ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការ ជាប្រក្រតីនៃស្ថាប័នជាតិ

## មាត្រាតែមួយ._

មាត្រា ៨២ មាត្រា ៨៨ថ្មី មាត្រា ៩០ថ្មី មាត្រា ៩៨ មាត្រា ១០៦ថ្មី មាត្រា ១១១ថ្មី (មួយ) មាត្រា ១១៤ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ត្រូវបានកែប្រែដូចតទៅ :

## មាត្រា ៨២ ._ ថ្មី

រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវប្រកាសសុពលភាព នៃអាណត្តិរបស់សមាជិកនីមួយៗ ត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានរដ្ឋសភា និង សមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង ដោយមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

តំណាងរាស្ត្រទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៥ នៃរដ្ឋធម្មនុញ្ញ ។

**មាត្រា ៨៨ ._ ថ្មី(ពីរ)**

ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ ។

រដ្ឋសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬ ពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬ ពីនាយករដ្ឋមន្ត្រី ។

ការប្រជុំរដ្ឋសភា នឹងយកជាការបានលុះត្រាតែមាន :

ក- កូរ៉ុមលើសពី ពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូលសម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើន ពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ខ- កូរ៉ុមលើសពីពាក់កណ្តាល នៃចំនួនសមាជិករដ្ឋសភាទាំងមូលសម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៩០ ._ ថ្មី(ពីរ)**

រដ្ឋសភាជាអង្គការ ដែលមានអំណាចនីតិបញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬ លុបចោលពន្ធដារ ។

រដ្ឋសភាឱ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រម ឬ លុបចោលសន្ធិសញ្ញា ឬ អនុសញ្ញាអន្តរជាតិ ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាលតាមមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

## មាត្រា ៩៨ .- ថ្មី

រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬ ទម្លាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញត្តិបន្ទោស តាមសំឡេងឆ្នោតភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន ។

## មាត្រា ១០៦ .- ថ្មី(មួយ)

ព្រឹទ្ធសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានព្រឹទ្ធសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

សមាជិកព្រឹទ្ធសភាទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី ៧ នៃរដ្ឋធម្មនុញ្ញ ។

**មាត្រា ១១១ .- ថ្មី(ពីរ)**

ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ ។

ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬ ពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬ ពីប្រធានរដ្ឋសភា ។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមាន :

ក-កូរ៉ុមលើសពី ពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើន ពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ខ-កូរ៉ុមលើសពីពាក់កណ្ដាលនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬ យកមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ចំនួនសំឡេងដែលតម្រូវសម្រាប់រដ្ឋសភាអនុម័តយល់ព្រម ហើយដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញត្រូវយកមកប្រើសម្រាប់ព្រឹទ្ធសភាផងដែរ ។

**មាត្រា ១១៤ .- ថ្មី(មួយ)**

ព្រឹទ្ធសភាបង្កើតគណៈកម្មការផ្សេងៗ ដែលចាំបាច់ ។ ការរៀបចំនិងការប្រព្រឹត្តទៅនៃព្រឹទ្ធសភានឹងកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា ។ បទបញ្ជាផ្ទៃក្នុងនេះត្រូវអនុម័តយល់ព្រម ដោយសំឡេងភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

**មាត្រា ៦ .— ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែម**

ការបោះឆ្នោតជាកញ្ចប់ខាងលើនេះ ត្រូវយកតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណីការបោះឆ្នោតជុំទីមួយមិនបានសម្រេច នីតិវិធីដដែលនេះនឹងត្រូវអនុវត្តចំពោះការបោះឆ្នោតជុំក្រោយៗទៀត ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០០៦

នស/រកម/០៣០៦/១៧៤ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ហត្ថលេខា**

**សុខ អាន**

លេខៈ ១១៣ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ៣ ឆ្នាំ២០០៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាង តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០២០៦/០៩៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ស៊ិន ហ៊ីតជេស៊ិន (SHEN HEATH JASON) ជនជាតិអាមេរិក សញ្ជាតិអាមេរិក កើតថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៧០ នៅរដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ ១០១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
ណារ៉ុ តាន់

៣រល.០៦០២.០៩៨

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៦

នស/រកត/០៣០៦/១០៧

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៩/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ត្រូវបានទទួលការប្រោសប្រទាននូវ គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ជូនមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ចំនួន ០៣ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបំរើ ជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :

១- លោក ប៉ុក សាឈុឃ
២- លោក សុខ សារេត
៣- លោក សរ ចំរុង

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស-០៦០៣.១១៧

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ . ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០០៦

លេខ: ១១៨ . ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវ តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៦/១០៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា )

## ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម ឧត្តមសេនីយ៍ឯក មល់ រឿប

នូវ

## គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.០៧០៣.១១៣

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ,ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០០៦

លេខៈ ៦៦៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាងី តាន់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...១៥៣...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន២៤គ្រឿង ប្រគេន និងជូនសប្បុរសជនរស់នៅក្នុង និងក្រៅប្រទេស ចំនួន២៤រូប ដែលបានបរិច្ចាគបច្ច័យ និងថវិកា ចូលរួមជួយកសាងព្រះវិហារថ្មី សាលាធម្មសភា ឧបដ្ឋានសាលា និងកុដិ នៅក្នុង ***វត្តភ្នំសំពៅ*** ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

១-ព្រះគ្រូធម្មាចារ្យ **គីម ម៉ិនឡៀន** ព្រះចៅអធិការវត្តភ្នំសំពៅ បច្ច័យចំនួន ៤២៧.២៣៩ ដុល្លារ

២-ឧបាសក **នួច ផន** សប្បុរសជននៅសហរដ្ឋអាមេរិក ថវិកាចំនួន ៣២.៣៨១ ដុល្លារ

៣-ព្រះតេជគុណ **គុជ ពុំ** គង់នៅសហរដ្ឋអាមេរិក បច្ច័យចំនួន ១៥.២២៦ ដុល្លារ

៤-នាង **មិត្រ សារឿន** សប្បុរសជននៅសហរដ្ឋអាមេរិក ថវិកាចំនួន ១៥.០៨០ ដុល្លារ

៥-ឧបាសិកា **ចេង យ៉ែន** សប្បុរសជននៅសហរដ្ឋអាមេរិក ថវិកា ចំនួន ២៦.៨៧២ ដុល្លារ

៦-លោក **អោ ពុំ** សប្បុរសជននៅសហរដ្ឋអាមេរិក ថវិកា ចំនួន ១៥.០០០ ដុល្លារ

៧-លោក **ខ្វាន់ ខួង** សប្បុរសជននៅសហរដ្ឋអាមេរិក ថវិកា ចំនួន ១៣.០០០ ដុល្លារ

៨-អ្នកស្រី **ប្រុម ចាំ** សប្បុរសជននៅសហរដ្ឋអាមេរិក ថវិកា ចំនួន ១៣.០០០ ដុល្លារ

៩-លោក **អ៊ុត ឌិម** សប្បុរសជនរស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន១៣.០០០ ដុល្លារ

១០-លោកអាចារ្យ **ហ៊ីន ម៉ិនផន** សប្បុរសជនរស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន១៣.០០០ដុល្លារ

**ខ.មេដាយប្រាក់ស្ថាបនាជាតិ :**

១-នាង **គូ ចំណាន** សប្បុរសជនរស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៨.០០០ ដុល្លារ

២-ឧបាសិកា **អោក យៀម.** សប្បុរសជនរស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៨.០០០ ដុល្លារ

៣-ឧបាសិកា **ប៊ិល ជៀន** សប្បុរសជនរស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៧.១០០ ដុល្លារ

៤-លោក **ជុំ ខន** សប្បុរសជនរស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៨.០០០ ដុល្លារ

៥-ឧបាសិកា **ប៉ែន ហៀក** សប្បុរសជនរស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៧.០០០ ដុល្លារ

៦-ឧបាសិកា **ខ្វាន់ ញិប** សប្បុរសជនរស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៦.០០០ ដុល្លារ

៧-ឧបាសិកា **អោក ហ៊ួន** សប្បុរសជនរស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៦.០០០ ដុល្លារ

៨-អ្នកស្រី **លឹម សួខ** សប្បុរសជនរស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៥.៤០០ ដុល្លារ

៩-លោក **យេន យួម** សប្បុរសជនរស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៥.៣០០ ដុល្លារ

១០-អ្នកស្រី **អ៊ឹម ស៊ីណាត** សប្បុរសជនរស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៥.០០០ ដុល្លារ

១១-លោក **កែវ ទៀត** សប្បុរសជនរស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៥.០០០ ដុល្លារ

១២-ឧបាសិកា **ម៉ក់ គួន** សប្បុរសជនរស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៥.០០០ ដុល្លារ

**គ.មេដាយសំរឹទ្ធស្ថាបនាជាតិ :**

១-អ្នកស្រី **ឃិន ចាន់** សប្បុរសជនរស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៣.៤២០ ដុល្លារ

២-ឧបាសិកា **ចៅ មុយ** សប្បុរសជនរស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ២.៥៧០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ៣ ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខៈ** ១៥៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **សេនា** ជូនលោក **ចេង ញ៉ាន់** នាយខុទ្ទកាល័យសាលាខេត្តកណ្តាល ដែលមានគុណបំណាច់ និងស្នាដៃល្អ ក្នុងការចូលរួមជួយកសាងហេដ្ឋារចនាសម្ព័ន្ធនានាក្នុងខេត្តកណ្តាល ។

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៥៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការនៅខេត្តកណ្តាល ចំនួន ៧០ នាក់ ដែលមានស្នាដៃឆ្នើមក្នុងការបំពេញភារកិច្ចក្នុងឆ្នាំ ២០០៥ ដូចមានរាយនាមខាងក្រោមនេះ :

***ក/ មេដាយមាសការងារ***

| | | |
|---|---|---|
| ១-លោក | សេខ សៀកហ៊ុយ | អភិបាលរងទី ២ ខេត្តកណ្តាល |
| ២-លោក | នខ សុគ្គា | អភិបាលរងខេត្តកណ្តាល |
| ៣-លោក | ហ៊ីខ ហាន | អភិបាលរងខេត្តកណ្តាល |
| ៤-លោក | សុត សុខ | នាយរងខុទ្ទកាល័យសាលាខេត្តកណ្តាល |
| ៥-លោក | អ៊ូ ចេង | អភិបាលស្រុក ខេត្តកណ្តាល |
| ៦-លោក | ចាន់ សុខុម | អភិបាលស្រុក ខេត្តកណ្តាល |
| ៧-លោក | ថែម ចិសុទ្ធ | អភិបាលស្រុក ខេត្តកណ្តាល |
| ៨-លោក | ខៀង សុខណាត | អភិបាលរងស្រុក ខេត្តកណ្តាល |
| ៩-លោក | ស៊ីថ្ល គីលីម | អភិបាលរងស្រុក ខេត្តកណ្តាល |
| ១០-លោក | គង់ សោភ័ណ្ឌ | អភិបាលរងស្រុក ខេត្តកណ្តាល |
| ១១-លោក | ខ៊ែត មុនី | អភិបាលរងស្រុក ខេត្តកណ្តាល |
| ១២-លោក | ជុន សុជាតិ | អភិបាលរងស្រុក ខេត្តកណ្តាល |

| | | |
|---|---|---|
| ១៣-លោក | ថ្វាំ សឿន | អភិបាលរងស្រុក ខេត្តកណ្តាល |
| ១៤-លោក | តាំង ម៉េងលាន | អភិបាលរងស្រុកមុខកំពូល ខេត្តកណ្តាល |
| ១៥-លោក | ពៅ សំបូរ | អភិបាលរងស្រុក ខេត្តកណ្តាល |
| ១៦-លោក | នូ សាខន | អភិបាលរងស្រុក ខេត្តកណ្តាល |
| ១៧-លោក | នួង ប៉េងច័ន្ទតារា | ប្រធានអង្គភាពរដ្ឋបាលមូលដ្ឋានសាលាខេត្តកណ្តាល |
| ១៨-លោក | សំ សូតី | អភិបាលរងស្រុក ខេត្តកណ្តាល |
| ១៩-លោក | ចយ សុបិន្ត | អភិបាលរងស្រុក ខេត្តកណ្តាល |
| ២០-លោក | ស៊ិន សារ៉េត | នាយរងក្រុមហិរញ្ញវត្ថុសាលាខេត្តកណ្តាល |
| ២១-លោកស្រី | សុខ វណ្ណា | នាយរងក្រុមហិរញ្ញវត្ថុសាលាខេត្តកណ្តាល |
| ២២-លោក | ទេព សូផន | លេខាធិការ ឯកឧត្តមអភិបាលខេត្តកណ្តាល |
| ២៣-លោក | សែន ឆេងឌី | ជំនួយការឯកឧត្តមអភិបាលរងទី ១ខេត្តកណ្តាល |
| ២៤-លោកស្រី | ចូ៉ង មួយគា | ប្រធានការិយាល័យសាលាខេត្តកណ្តាល |
| ២៥-លោក | តែ ខួន | ប្រធានការិយាល័យសាលាខេត្តកណ្តាល |
| ២៦-លោក | ជា លន | ប្រធានការិយាល័យសាលាខេត្តកណ្តាល |
| ២៧-លោក | សែ ជុនទ្រី | ប្រធានការិយាល័យសាលាខេត្តកណ្តាល |
| ២៨-លោក | ជន ហេង | អនុប្រធានការិយាល័យសាលាខេត្តកណ្តាល |
| ២៩-លោកស្រី | សាវ៉ិន វ៉េន | អនុប្រធានការិយាល័យសាលាខេត្តកណ្តាល |
| ៣០-លោកស្រី | ជា សុផាន់ណា | អនុប្រធានការិយាល័យសាលាខេត្តកណ្តាល |
| ៣១-លោក | មួន ស៊ាន | អនុប្រធានការិយាល័យសាលាខេត្តកណ្តាល |
| ៣២-លោក | ឆេង ផា | អនុប្រធានការិយាល័យសាលាខេត្តកណ្តាល |
| ៣៣-លោក | ស្រ៊ុន ហេងចន់ | មន្ត្រីសាលាខេត្តកណ្តាល |
| ៣៤-លោក | អ៊ិត ជារ៉េត | អនុប្រធានការិយាល័យសាលាខេត្តកណ្តាល |
| ៣៥-លោក | ខឹម សុភាព | មន្ត្រីសាលាខេត្តកណ្តាល |
| ៣៦-លោក | ស្វាយ សំអាត | មន្ត្រីសាលាខេត្តកណ្តាល |
| ៣៧-លោកស្រី | សុខ វិចេក | មន្ត្រីសាលាខេត្តកណ្តាល |
| ៣៨-លោកស្រី | ប៉ុស សុភាព | មន្ត្រីសាលាខេត្តកណ្តាល |
| ៣៧-លោកស្រី | ប៊ុន រមណី | ប្រធានមន្ទីរស្រុកតាខ្មៅ ខេត្តកណ្តាល |
| ៤០-លោក | យិន សំ | ប្រធានមន្ទីរស្រុក ខេត្តកណ្តាល |

*ខ/ មេដាយប្រាក់ការងារ*

| | | |
|---|---|---|
| ១-លោកស្រី | ជិន គឹមអេង | មន្ត្រីសាលាខេត្តកណ្តាល |
| ២-លោក | ជួប ប៊ុនធឿន | មន្ត្រីសាលាខេត្តកណ្តាល |
| ៣-លោក | សោ ផា | មន្ត្រីសាលាខេត្តកណ្តាល |
| ៤-លោកស្រី | អ៊ុន សុគន្ធា | មន្ត្រីសាលាខេត្តកណ្តាល |
| ៥-លោកស្រី | ខែ៉ត សុវណ្ណវុឌ្ឍី | មន្ត្រីសាលាខេត្តកណ្តាល |
| ៦-លោក | វ៉ាន់ សុផល | មន្ត្រីសាលាខេត្តកណ្តាល |
| ៧-លោកស្រី | ទូច សាលឹម | មន្ត្រីសាលាខេត្តកណ្តាល |
| ៨-លោកស្រី | សាន ហ៊ាញ | មន្ត្រីសាលាខេត្តកណ្តាល |
| ៩-លោកស្រី | ទី សុខខន្តី | មន្ត្រីសាលាខេត្តកណ្តាល |
| ១០-លោកស្រី | ម៉ិច យិចគី | មន្ត្រីសាលាខេត្តកណ្តាល |

| | | |
|---|---|---|
| ១១-លោក | សុខ វ៉ា | អនុប្រធានមន្ទីរ ខេត្តកណ្តាល |
| ១២-លោក | គង់ ផាន់ | អនុប្រធានមន្ទីរ ខេត្តកណ្តាល |
| ១៣-លោក | អ៊ុច ចិនគីម | ប្រធានការិយាល័យសាលាស្រុក ខេត្តកណ្តាល |
| ១៤-លោក | ជូ ប៊ុនធន | ប្រធានការិយាល័យសាលាស្រុកមុខកំពូល ខេត្តកណ្តាល |
| ១៥-លោក | ម៉ា រុន | ប្រធានការិយាល័យសាលាស្រុកមុខកំពូល ខេត្តកណ្តាល |
| ១៦-លោកស្រី | គង សុមនី | ប្រធានការិយាល័យសាលាស្រុក ខេត្តកណ្តាល |
| ១៧-លោក | ជិន ជឿន | ប្រធានការិយាល័យសាលាស្រុកតាខ្មៅ ខេត្តកណ្តាល |
| ១៨-លោកស្រី | ម៉ុល មាលី | ប្រធានការិយាល័យសាលាស្រុក ខេត្តកណ្តាល |
| ១៩-លោក | ជួប ឫទ្ធី | អនុប្រធានការិយាល័យសាលាស្រុកមុខកំពូល ខេត្តកណ្តាល |
| ២០-លោក | ចាប ធឿង | អនុប្រធានការិយាល័យសាលាស្រុកកោះធំ ខេត្តកណ្តាល |
| ២១-លោក | សាំង ចេក | អនុប្រធានការិយាល័យសាលាស្រុកកោះធំ ខេត្តកណ្តាល |
| ២២-លោក | សរ វណ្ណឌី | អនុប្រធានការិយាល័យសាលាស្រុកតាខ្មៅ ខេត្តកណ្តាល |
| ២៣-លោក | ម៉ែន នីច័ន | អនុប្រធានការិយាល័យសាលាស្រុកតាខ្មៅ ខេត្តកណ្តាល |
| ២៤-លោក | យិន សុផេន | អនុប្រធានការិយាល័យសាលាស្រុកលើកដែក ខេត្តកណ្តាល |
| ២៥-លោក | សួង កែប | មន្ត្រីសាលាស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល |
| ២៦-លោកស្រី | ឡុង ណារី | មន្ត្រីសាលាស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល |
| ២៧-លោក | ម៉ោល គីមមន | មន្ត្រីសាលាស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល |
| ២៨-លោក | កុយ ធុក | មន្ត្រីសាលាស្រុកមុខកំពូល ខេត្តកណ្តាល |
| ២៩-លោក | ម៉ឿន សាឆន | មន្ត្រីសាលាស្រុកតាខ្មៅ ខេត្តកណ្តាល |
| ៣០-លោក | គង់ សារឿន | មន្ត្រីសាលាស្រុកតាខ្មៅ ខេត្តកណ្តាល |

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ០៣ ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
អគ្គលេខាធិការរាជរដ្ឋាភិបាល
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ដូចមាត្រា ១ និងមាត្រា ២
ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខៈ** ២៥៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការនៅខេត្តឧត្តរមានជ័យ ចំនួន ២១ នាក់ ដែលមានស្នាដៃឆ្នើម ក្នុងការបំពេញភារកិច្ចក្នុងឆ្នាំ ២០០៥ ដូចមានរាយនាមខាងក្រោមនេះ :

ក_ មេដាយមាសការងារ

| | | |
|---|---|---|
| ១-លោក | សាន ចណ្ណា | អភិបាលរងទី ២ ខេត្តឧត្តរមានជ័យ |
| ២-លោក | ភាន រិទ្ធី | អភិបាលរងខេត្តឧត្តរមានជ័យ |
| ៣-លោក | គីម តុម | អភិបាលស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ |
| ៤-លោក | ចណ្ណា កុសល | អភិបាលស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ |
| ៥-លោក | ចាប ផាត | អភិបាលរងស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ |

ខ_ មេដាយប្រាក់ការងារ

| | | |
|---|---|---|
| ១-លោក | ហាំង ម៉េង | នាយរងខុទ្ទកាល័យសាលាខេត្តឧត្តរមានជ័យ |
| ២-លោក | មុត ចុង | អភិបាលរងស្រុកសំរោង ខេត្តឧត្តរមានជ័យ |
| ៣-លោក | ស្វាយ ហ៊ី | អភិបាលរងស្រុកសំរោង ខេត្តឧត្តរមានជ័យ |
| ៤-លោក | សុខ នាម | អភិបាលរងស្រុកសំរោង ខេត្តឧត្តរមានជ័យ |

៥-លោក ហៀប ប៊ុនណារិទ្ធិ មន្ត្រីការិយាល័យបុគ្គលិកសាលាខេត្តឧត្តរមានជ័យ

គ-. មេជាយសីវិន្ថិការខារ

១-លោក ហ៊ិខ ហឿន អភិបាលរងស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ

២-លោក ផន កុត អភិបាលរងស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ

៣-លោក សៅ ថាន អភិបាលរងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

៤-លោក ញឿយ សារឿន អភិបាលរងស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ

៥-លោក ជិន សាថន់ អភិបាលរងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

៦-លោក ជុំ ស៊ិម អគ្គលេខាធិការសាលាខេត្តឧត្តរមានជ័យ

៧-លោក នៀត្រ ដារ៉ា នាយរងខុទ្ទកាល័យសាលាខេត្តឧត្តរមានជ័យ

៨-លោក ខ៊ិ សុធាព នាយរងក្រុមហិរញ្ញវត្ថុសាលាខេត្តឧត្តរមានជ័យ

៩-លោក ខាំ វិសាល ប្រធានការិយាល័យកិច្ចការភូមិបាលសាលាខេត្តឧត្តរមានជ័យ

១០-លោក សេខ ថុល អនុប្រធានការិយាល័យកិច្ចការទូទៅសាលាខេត្តឧត្តរមានជ័យ

១១-លោក គង់ សន អនុប្រធានការិយាល័យសរុបសាលាខេត្តឧត្តរមានជ័យ

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ . ថ្ងៃទី ០៦ ខែ ០២ ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ១៥៧ អនក្រ.សក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនឯកឧត្តម អស់លោកចំនួន ០៨ នាក់ ដែលបានបំពេញភារកិច្ច ប្រកបដោយស្មារតីទទួលខុសត្រូវ សំរេចបានលទ្ធផល និងស្នាដៃធំ ៗ ជាច្រើនលើគ្រប់វិស័យទូទាំងខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោមនេះ :

ក/ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា

| | | |
|---|---|---|
| ១ | ឯកឧត្តម ម៉ែន អ៊ាន | អភិបាលរងខេត្តព្រៃវែង |
| ២ | លោក ផា ខួនគា | អភិបាលរងខេត្តព្រៃវែង |
| ៣ | លោក ម៉ុក កាណែល | អភិបាលរងខេត្តព្រៃវែង |
| ៤ | លោក សុខ្ល សឺន | អភិបាលរងខេត្តព្រៃវែង |
| ៥ | លោក យោគ ស៊ីថុន | អភិបាលរងខេត្តព្រៃវែង |
| ៦ | លោក ម៉ិន សំអុល | អភិបាលរងខេត្តព្រៃវែង |
| ៧ | លោក ថ្នាក់ ឌឿន | អភិបាលរងខេត្តព្រៃវែង |

**ខ/ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ**

១ លោក ឆេព បូរី នាយខុទ្ទកាល័យសាលាខេត្តព្រៃវែង

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ . ថ្ងៃទី ០[illegible] ខែ [illegible] ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

*ក្រសួងព្រះបរមរាជវាំង*
*អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*អគ្គលេខាធិការរាជរដ្ឋាភិបាល*
*ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*ដូចមាត្រា ១ និងមាត្រា ២*
*ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ១៥៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៩/០១ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ១៩៩៩ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការសាលាខេត្ត សាលាស្រុក កងកំលាំងប្រដាប់អាវុធ មន្ទីរ អង្គភាពនានានៅខេត្តព្រៃវែង ចំនួន ៤២ នាក់ ដែលមានស្នាដៃឆ្នើម ក្នុងការបំពេញភារកិច្ចក្នុងឆ្នាំ២០០៥ ដូចមានរាយនាមខាងក្រោមនេះ :

**ក_ មេដាយមាសការងារ**

| | | |
|---|---|---|
| ១-លោកឧ.ត្រី | នឹម ផន | ស្នងការ នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង |
| ២-លោកវ.ឯក | ហ៊ុ ហ៊ន | មេបញ្ជាការតំបន់សឹករងខេត្តព្រៃវែង |
| ៣-លោកវ.ឯក | សុខ គ្រឹន | មេបញ្ជាការ នៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តព្រៃវែង |
| ៤-លោក | កែវ សេន | អភិបាលស្រុកកំពង់លាវ ខេត្តព្រៃវែង |
| ៥-លោក | ស៊ិន សារៈ | អភិបាលស្រុកពារាំង ខេត្តព្រៃវែង |
| ៦-លោក | ហាឡុ សាធុន | អភិបាលស្រុកមេសាង ខេត្តព្រៃវែង |
| ៧-លោក | ជា ស្រូយ | អភិបាលស្រុកព្រះស្តេច ខេត្តព្រៃវែង |
| ៨-លោក | ម៉ូ សារូ | អភិបាលស្រុកកំពង់ត្របែក ខេត្តព្រៃវែង |

| | | |
|---|---|---|
| ៩-លោក | ឡុង ថាត | អភិបាលស្រុកកំចាយមារ ខេត្តព្រៃវែង |
| ១០-លោក | ពុត សារុន | អភិបាលស្រុកព្រៃវែង ខេត្តព្រៃវែង |
| ១១-លោក | ម៉ៅ អ៊ាង | អភិបាលស្រុកបាភ្នំ ខេត្តព្រៃវែង |
| ១២-លោក | ខៀវ សុខន | អភិបាលស្រុកពាមរក៍ ខេត្តព្រៃវែង |
| ១៣-លោក | ស៊ាង ប៊ុន្លា | អភិបាលស្រុកកញ្ជ្រៀច ខេត្តព្រៃវែង |
| ១៤-លោក | សោម រតនះ | នាយក្រុមហិរញ្ញវត្ថុសាលាខេត្តព្រៃវែង |
| ១៥-លោក | ឡាក់ សេង | អធិការ នៃក្រុមអធិការកិច្ចសាលាខេត្តព្រៃវែង |
| ១៦-លោក | ម៉ារ សារីន | អធិការរងទី ១ នៃក្រុមអធិការកិច្ចសាលាខេត្តព្រៃវែង |
| ១៧-លោក | ឡាច តីវ៉ាត់ | នាយរងក្រុមហិរញ្ញវត្ថុសាលាខេត្តព្រៃវែង |
| ១៨-លោក | ទេព ធណ្ណី | នាយរងក្រុមហិរញ្ញវត្ថុសាលាខេត្តព្រៃវែង |
| ១៩-លោក | ឡុង ចន្ថា | នាយរងក្រុមហិរញ្ញវត្ថុសាលាខេត្តព្រៃវែង |
| ២០-លោក | ជុំ សារឿន | អគ្គលេខាធិការរងសាលាខេត្តព្រៃវែង |
| ២១-លោក | សុខ សាយ | ប្រធានមន្ទីរសាធារណការខេត្តព្រៃវែង |
| ២២-លោក | ទេព សាម៉ន | ប្រធានរតនាគារខេត្តព្រៃវែង |
| ២៣-លោក | ទួន ប៊ុនថន | ទីប្រឹក្សាក្រសួងកសិកម្ម |
| ២៤-លោក | សុខ ឆាង | ប្រធានមន្ទីរផែនការខេត្តព្រៃវែង |
| ២៥-លោក | ស សែត | ប្រធានមន្ទីរធម្មការ សាសនាខេត្តព្រៃវែង |
| ២៦-លោក | លី មុន្នីនាថ | ប្រធានមន្ទីរប្រៃសណីយ៍ខេត្តព្រៃវែង |
| ២៧-លោក | ហ៊ឹម សុផល | ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែង |
| ២៨-លោក | គូ យឿន | ប្រធានមន្ទីរពាណិជ្ជកម្មខេត្តព្រៃវែង |
| ២៩-លោក | សុខ ផេង | ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្តព្រៃវែង |
| ៣០-លោក | ឈួន ឡេង | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តព្រៃវែង |
| ៣១-លោក | កេត ឈាន | ប្រធានមន្ទីរពត៌មានខេត្តព្រៃវែង |
| ៣២-លោក | ជា សារឹម | ប្រធានមន្ទីរវប្បធម៌ខេត្តព្រៃវែង |
| ៣៣-លោក | យិន សារឿន | ប្រធានមន្ទីរសង្គមកិច្ចខេត្តព្រៃវែង |
| ៣៤-លោក | ធូ អ៊ី | មន្ត្រីគ្រប់គ្រងរដ្ឋបាល មន្ទីរបរិស្ថានខេត្តព្រៃវែង |
| ៣៥-លោក | អេង ឆ៉ាក់ | ប្រធានមន្ទីរទេសចរណ៍ខេត្តព្រៃវែង |
| ៣៦-លោកស្រី | ងិម ផល្លា | ប្រធានមន្ទីរកិច្ចការនារីខេត្តព្រៃវែង |
| ៣៧-លោក | ជឹម យុន្នី | ប្រធានសាខាពន្ធដារខេត្តព្រៃវែង |
| ៣៨-លោក | ខាត់ ចន | ប្រធានមន្ទីធនធានទឹក និងឧតុនិយមខេត្តព្រៃវែង |
| ៣៩-លោក | ពេជ្រ ហ៊ាន់ | ប្រធានមន្ទីរសុខាភិបាលខេត្តព្រៃវែង |
| ៤០-លោក | អ៊ុក អ៊ា | ប្រធានមន្ទីរទំនាក់ទំនងជាមួយព្រឹទ្ធសភារដ្ឋសភានិងអធិការកិច្ចខេត្តព្រៃវែង |

៤១-លោក សួន សុគន្ធ ប្រធានអង្គភាពអគ្គិសនីខេត្តព្រៃវែង

៤២-លោក យស់ ចាន់ថុល ប្រធានសាខាធនាគារខេត្តព្រៃវែង

**មាត្រា ២** : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ . ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

*ស្ងួងព្រះបរមរាជវាំង*
*រលេខាធិការដ្ឋានព្រឹទ្ធសភា*
*រលេខាធិការដ្ឋានរដ្ឋសភា*
*រលេខាធិការរាជរដ្ឋាភិបាល*
*កាល័យសម្តេចនាយករដ្ឋមន្ត្រី*
*មាត្រា ១ និងមាត្រា ២*
*សារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ២៧៩ ឧរថ.កវ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០៦

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៤៩៥/០៦ គ.វ.ក ចុះថ្ងៃទី០៦.០២.២០០៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន នីមប៊ីស ថិចថាយ (ខេមបូឌា) ចុះថ្ងៃទី២៤.០១.២០០៦

# សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន នីមប៊ីស ថិចថាយ (ខេមបូឌា) (NIMBUS TEXTILE (CAMBODIA) CO., LTD.) តំណាងដោយ លោក WANG WENFANG សញ្ជាតិចិន អាយុ៣៦ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G03283187 ចុះថ្ងៃទី១៤.១២.២០០១ បង្កើតរោងចក្រ"កាត់ដេរសម្លៀកបំពាក់"ដែលមានឈ្មោះថា " នីមប៊ីស ថិចថាយ (ខេមបូឌា) (NIMBUS TEXTILE (CAMBODIA))" មានទីតាំងស្ថិតនៅ ភូមិព្រៃរការ ឃុំធក់ឈើនាង ស្រុកអង្គស្នួល ខេត្តកណ្តាល ។

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាព ផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

